

# ការបង្កើតសហគ្រាសខ្នាតតូចសម្រាប់អ្នកក្រីក្រនៅរាជធានីភ្នំពេញ

## សាវតាគម្រោង

អ្នកក្រីក្រនៅរាជធានី និងនៅតាមជាយរាជធានី(បុគ្គលដែលរស់នៅលើចំណែកដីតូចៗនៅតាមជាយរាជធានី) ស្ថិតក្នុងចំណោមប្រជាពលរដ្ឋចំនួន៤០.០០០គ្រួសារ ដែលរស់នៅក្នុងភាពក្រីក្របំផុតនៅរាជធានីភ្នំពេញ។ ប្រជាពលរដ្ឋទាំងនេះជាច្រើននាក់ ចូលមករាជធានីភ្នំពេញ ដើម្បីស្វែងរកឱកាសសេដ្ឋកិច្ច ប៉ុន្តែពួកគេច្រើនតែមានការសិក្សាកម្រិតទាប គ្មានធនធានហិរញ្ញវត្ថុ និងកង្វះជំនាញសំខាន់ៗ សម្រាប់ទ្រទ្រង់របរចិញ្ចឹមជីវិតរបស់ខ្លួន។ ជាផលវិបាកប្រជាពលរដ្ឋទន់ខ្សោយទាំងនេះងាយរងគ្រោះបំផុត ដោយសារតែឥទ្ធិពលនៃអសន្តិសុខស្បៀង តម្លៃខ្ពស់នៃស្បៀងអាហារ ពុំមានស្បៀងអាហារគ្រប់គ្រាន់ ការប្រែប្រួលអាកាសធាតុ និងភាពគ្មានផ្ទះសំបែង។

ទោះបីនៅរាជធានីភ្នំពេញ មានស្បៀងសំបូរហូរហៀរក៏ដោយ អ្នកក្រីក្រជាច្រើនក្នុងរាជធានីភ្នំពេញខ្វះប្រាក់ ដោយសារតែការពឹងផ្អែកលើប្រាក់តិចតួចដែលពួកគេមានប៉ុណ្ណោះ។ ជាលទ្ធផលពួកគេមិនអាចទិញអាហារ ដែលមានគុណភាពល្អប្រកបដោយសារជាតុបំប៉នឡើយ និងត្រូវពឹងផ្អែកតែលើអាហារដែលទិញប្រចាំថ្ងៃ ដែលជាកត្តាចំបងនៃអសន្តិសុខស្បៀងប្រចាំគ្រួសារ។ អ្នកក្រីក្រទាំងនេះក្លាយជាសហគមន៍ទន់ខ្សោយ ដែលជាញឹកញាប់ពុំមានជម្រើសអាហារសម្រាប់ការទទួលទានឡើយ និងជាញឹកញាប់អាហាររបស់ពួកគេពុំមានសុវត្ថិភាព និងមានគុណភាពទាប។

## អសន្តិសុខស្បៀងក្នុងចំណោមអ្នកក្រីក្រនៅរាជធានី

អសន្តិសុខស្បៀង គឺជាបញ្ហារបស់អ្នករស់នៅក្នុងរាជធានីដែលធ្វើការនៅក្នុងសេដ្ឋកិច្ចមិនរៀបរយ ជាអាទិ៍ ការកែច្នៃសម្រាមបម្រើការតាមភោជនីយដ្ឋាន ការដឹកជញ្ជូន (អ្នករត់ស៊ីក្លូ រ៉ឺម៉ក និងម៉ូតូឌុប) កម្មករបម្រើការតាមផ្ទះ និងកម្មករសំណង់ អ្នកលក់ដូរតូចតាច ដែលរួមទាំង អ្នកកាត់ដេរជាលក្ខណៈគ្រួសារ អ្នកលក់អាហារតាមចិញ្ចើមថ្នល់ អ្នកកែច្នៃត្រី និងអ្នកកែច្នៃម្ហូបតិចតួច។ ដោយសារតែកង្វះប្រាក់ចំណូលទៀងទាត់ប្រចាំខែ ពួកគេមិនអាចគ្រោងជាមុនអំពីថាតើពួកគេនឹងមានអាហារបរិភោគនៅពេលណាឡើយ (ពួកគេអាចមាន ឬគ្មានអាហារបរិភោគ)។ ពួកគេរកបានប្រាក់ចំណូលមិនគ្រប់គ្រាន់សម្រាប់ទិញ ឬដាំដំណាំដែលផ្តល់ជាស្បៀងអាហារឲ្យគ្រប់គ្រាន់សម្រាប់បរិភោគឡើយ។ ជាសំណាងអាក្រក់ អ្នកក្រីក្រនៅរាជធានីពុំមានប្រាក់ ឬជំនាញសម្រាប់កែលម្អ លទ្ធភាពទទួលបានស្បៀងអាហារ និងកែលម្អរបរចិញ្ចឹមជីវិតឡើយ។ នេះជាហេតុផលដែលគម្រោងនេះត្រូវបានបង្កើតឡើង ដោយមានគោលដៅជាក់លាក់ អំពីការបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងខណ្ឌក្រីក្រចំនួនពីរ ក្នុងរាជធានីភ្នំពេញគឺ ខណ្ឌមានជ័យ និងខណ្ឌឫស្សីកែវ។

## គោលបំណងរបស់គម្រោង

នេះជាគម្រោងដំបូងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ដែលដោះស្រាយបញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់អ្នកក្រីក្រក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា។ គម្រោងនេះ មានគោលដៅលើកកម្ពស់សន្តិសុខស្បៀងរបស់គ្រួសារក្រីក្រ តាមរយៈកំណើនផលិតភាពកសិកម្មប្រាក់ចំណូលប្រចាំគ្រួសារ និងការយល់ដឹងអំពីសុខភាព និងអាហារូបត្ថម្ភ។



European Union

គម្រោងនេះ នឹងផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ពលរដ្ឋទន់ខ្សោយប្រមាណ ២.៥០០គ្រួសារ ក្នុង៣៧ភូមិ នៅរាជធានីភ្នំពេញ។

ភាពជោគជ័យ និងបរាជ័យនៃសកម្មភាពក្នុងគម្រោងនេះ នឹងត្រូវវាយតម្លៃ និងវិភាគសម្រាប់ជាមូលដ្ឋានដើម្បីលើកអនុសាសន៍ដែលទាក់ទងនឹងគោលនយោបាយ និងការអនុវត្តផែនការសកម្មភាពសម្រាប់កែលម្អសន្តិសុខស្បៀងក្នុងចំណោមអ្នកក្រីក្រនៅរាជធានី។

## ម្ចាស់ជំនួយ និងភាពជាដៃគូ

គម្រោងនេះ ទទួលថវិកាបដិភាគពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) និងសហភាពអឺរ៉ុប (EU) ដោយមានថវិកាចំនួន ១,២៥លានអឺរ៉ូ។ គម្រោងនេះអនុវត្ត តាមរយៈភាពជាដៃគូជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផលសាលារាជធានីភ្នំពេញ ខណ្ឌរដ្ឋបាលជលផលរាជធានីភ្នំពេញ មន្ទីរកសិកម្មរាជធានីភ្នំពេញនិងអង្គការសហគមន៍មូលដ្ឋាន(CBO)។

## អង្គការ FAO គាំទ្រដល់សកម្មភាពផ្សេងៗគ្នាជាច្រើន

អង្គការ FAO និងដៃគូសំខាន់ៗ នឹងផ្តល់ជំនាញ និងការបណ្តុះបណ្តាលអំពីបច្ចេកទេស មុខរបរ និងសហគ្រាស ដល់អ្នកទទួលផលចំនួន២ ៥០០នាក់។ សកម្មភាពសំខាន់ៗមានជាអាទិ៍ ការបង្កើតមណ្ឌលនៅក្នុងខណ្ឌចំនួនពីរ សម្រាប់ការបណ្តុះបណ្តាល អំពីការកែច្នៃចំណីអាហារ។ លើសពីនេះ វគ្គបណ្តុះបណ្តាលដោយឡែក និងការអនុវត្តជាក់ស្តែងនៅក្នុងផលិតកម្មកសិកម្ម ដែលរួមទាំងបច្ចេកទេសដាំដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ក៏នឹងមានផ្តល់ជូនផងដែរ។ លទ្ធផលពីសកម្មភាពទាំងនេះនឹងត្រូវផ្សារភ្ជាប់ជាមួយទីផ្សារកសិផលដែលបង្កើតឡើងនៅក្នុងខណ្ឌនីមួយៗ។

គោលដៅចំបងមួយនៃគម្រោងនេះ គឺជួយអ្នកក្រីក្រក្នុងរាជធានីបង្កើនប្រាក់ចំណូល ដើម្បីទ្រទ្រង់ការចិញ្ចឹមជីវិតរបស់ខ្លួន។ ដើម្បីធ្វើបែបនេះបាន គម្រោងនឹងសិក្សាលទ្ធភាពខាងទីផ្សារក្នុងនាមអ្នកទទួលផល ដើម្បីពួកគេអាចបង្កើនប្រាក់ចំណូលតាមរយៈការលក់ផលិតផលរបស់ពួកគេ។ គន្លឹះនៃភាពជោគជ័យក្នុងមុខរបរ គឺដើមទុន។ ដូច្នេះមុខរបរឥតសំណងខ្នាតតូចនឹងត្រូវផ្តល់ និងបង្កើតឲ្យមានចំណងទាក់ទងរវាងអ្នកទទួលផល និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីអ្នកទទួលផល អាចទទួលបានឥណទានសម្រាប់ទិញសម្ភារៈដែលចាំបាច់ ឬពង្រីកដើមទុនសម្រាប់ដំណើរការមុខរបររបស់ពួកគេ។

គម្រោងនេះធ្វើការលើកកម្ពស់សមធម៌យេនឌ័រ ដោយសង្កត់ធ្ងន់លើគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ក៏ដូចជាអ្នកធ្វើចំណាកស្រុក និងក្រុមជនជាតិភាគតិចផងដែរ។

## សមិទ្ធផលរំពឹងទុក

សមិទ្ធផលរំពឹងទុកនៃគម្រោងនេះគឺៈ

- ២ ៥០០គ្រួសារបានកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- អ្នកមានដីតូចតាចមានកំណើនផលដំណាំ និងសត្វចិញ្ចឹម
- អ្នកទទួលផល រួមទាំងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងក្រុមជនជាតិភាគតិច មានជំនាញបង្កើតមុខរបរ
- បានបង្កើតឱកាសទីផ្សារសម្រាប់អ្នកក្រីក្រដើម្បីរកប្រាក់ចំណូល
- បង្កើនសមត្ថភាពរបស់អ្នកក្រីក្រ ដើម្បីវិនិយោគលើការពង្រីក និងបង្កើនសកម្មភាពចិញ្ចឹមជីវិត
- អ្នកទទួលផលបានកែលម្អការអនុវត្តដែលទ្រទ្រង់សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ
- អនុសាសន៍សម្រាប់គោលនយោបាយអំពីសន្តិសុខស្បៀងសម្រាប់អ្នកក្រីក្រនៅរាជធានី និងតាមជាយរាជធានី។







European Union